# ជំនួយដើម្បីឲ្យអ្នកអាចជួល និងស្នាក់នៅក្នុងផ្ទះជួលបាន

## ជំនួយសម្រាប់អ្នកជួលផ្ទះស្នាក់នៅ

សូមពិភាក្សាជាមួយយើងខ្ញុំ ប្រសិនបើអ្នកត្រូវការជំនួយលើថ្លៃជួលផ្ទះ ឬថ្លៃគេហកិច្ចរបស់អ្នក ។ យើងខ្ញុំ មានផ្ដល់ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់ពលរដ្ឋ ដើម្បីឲ្យពួកគេអាចចូលនៅ ឬអាចស្នាក់នៅក្នុងផ្ទះជួលឯកជនបាន ។ នេះគឺរួមបញ្ចូលទាំងនិស្សិត និងពលរដ្ឋដែលមានអាយុលើសពី 65 ឆ្នាំ ។

អ្នកមិនចាំបាច់ជាពលរដ្ឋដែល ទទួលបានជំនួយពីរដ្ឋាភិបាល ទើបអាចមានសិទ្ធិទទួលបានជំនួយនេះឡើយ ។ អ្នកក៏អាចមានសិទ្ធិទទួលបានជំនួយនេះដែរ ប្រសិនបើអ្នក ជាពលរដ្ឋមានប្រាក់ចំណូលទាប ។

ជំនួយគាំទ្រដែលអ្នកទទួលបាន គឺអាស្រ័យលើស្ថានភាព ប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់អ្នក ។

### ជំនួយដែលកំពុងផ្ដល់ជូនបន្ត ចំពោះការជួលផ្ទះស្នាក់នៅ

ប្រសិនបើអ្នកត្រូវការជំនួយដើម្បីបង់ថ្លៃជួលផ្ទះឯកជន ឬផ្ទះនៅរួមគ្នា អ្នកអាចទទួលបានជំនួយនេះ ដែលគេហៅថា ជំនួយបង្គ្រប់ផ្នែកទីជម្រកស្នាក់នៅ ។ ជំនួយនេះ មិនមានផ្ដល់ជូន ចំពោះអ្នក ដែលស្នាក់នៅក្នុងលំនៅដ្ឋានសាធារណៈ ឡើយ ។

ប្រសិនបើអ្នកត្រូវការជំនួយបន្ថែមទៀត សម្រាប់បង់ថ្លៃការជួលផ្ទះរបស់អ្នក ឬជំនួយសម្រាប់បង់ថ្លៃចំណាយលើការរស់នៅសំខាន់ៗផ្សេងទៀត អ្នកក៏អាចទទួលបានជំនួយបន្ថែមបណ្ដោះអាសន្ន ផងដែរ ។ ជំនួយនេះ អាចផ្ដល់ជូនអ្នក រហូតដល់ 13 សប្ដាហ៍ ក្នុងមួយលើក ។

### ការបង់ថ្លៃជួលផ្ទះ ដែលហួសកាលកំណត់

ប្រសិនបើអ្នក មិនអាចបង់ថ្លៃជួលផ្ទះតាមកាលកំណត់បានទេ  សូមរួសរាន់ស្វែងរកជំនួយ ។  សូមពិភាក្សាជាមួយម្ចាស់ផ្ទះ របស់អ្នក អំពី ផែនការ ក្នុងការបង់ថ្លៃជួលផ្ទះ ដែលហួសពេល របស់អ្នក ។ ប្រសិនបើសកម្មភាពនេះ មិនអាចដំណើរការទៅរួច យើងខ្ញុំអាចជួយអ្នកបាន ដើម្បីកុំឱ្យគេបណ្ដេញអ្នកចេញពីផ្ទះ ។

អ្នកអាចទទួលបានជំនួយហិរញ្ញវត្ថុសម្រាប់បង់ថ្លៃផ្ទះជួល ដែលហួសកាលកំណត់ ។ តែអ្នកត្រូវសងប្រាក់នេះមកវិញ នៅពេលក្រោយ

### ការបង់ប្រាក់កក់ និងការបង់ថ្លៃជួលផ្ទះ ជាមុន

ប្រសិនបើអ្នក រកបានផ្ទះសម្រាប់ជួលស្នាក់នៅហើយ យើងខ្ញុំអាចជួយអ្នកបាន ក្នុងការបង់ប្រាក់កក់ និងបង់ថ្លៃជួលផ្ទះ ជាមុន ។

សូមពិភាក្សាជាមួយយើងខ្ញុំ ហើយយើងខ្ញុំនឹងពិចារណាមើលថា តើអ្នកអាចទទួលបានជំនួយអ្វីខ្លះ ។ ជំនួយនេះ គឺអាចជួយក្នុងការបង់ប្រាក់កក់ និងការបង់ថ្លៃជួលផ្ទះ ជាមុន ។ តែអ្នកត្រូវសងប្រាក់នេះមកវិញ នៅពេលក្រោយ

MINISTRY OF SOCIAL DEVELOPMENT
TE MANATŪ WHAKAHIATO ORA

WORK AND INCOME
TE HIRANGA TANGATA

SHA334W-Khmer – OCT 2023

### ការរើផ្ទះទៅនៅកន្លែងផ្សេង

ប្រាក់ជំនួយថ្លៃរើផ្ទះ អាចជួយអ្នក ដូចជា ជួយចេញថ្លៃជួលរទេះអូស ឬជួលឡានដឹក តវ៉ាន់ ។ ប្រាក់ជំនួយនេះ ក៏អាចយកទៅប្រើសម្រាប់បង់ថ្លៃកម្មកររើផ្ទះ បានដែរ ប្រសិនបើអ្នកមិនអាច ធ្វើកិច្ចការនេះដោយខ្លួនឯងបាន, ឧទាហរណ៍ ដោយសារអ្នកជាមនុស្សចាស់ជរា មានជំងឺ ឬជាជន មានពិការភាពជាប់ខ្លួន ។

តែអ្នកត្រូវ សងប្រាក់នេះមកវិញ នៅពេលក្រោយ

### ជួយរកផ្ទះជួលឲ្យអ្នក

ប្រសិនបើអ្នកកំពុងស្វែងរកផ្ទះជួលសម្រាប់រស់នៅ ប៉ុន្តែពិបាករក ដោយសារតែស្ថានភាពផ្ទាល់ខ្លួនរបស់អ្នក យើងខ្ញុំអាចជួយអ្នកបាន ដោយចេញសំបុត្រធានាតម្លៃជួល សម្រាប់យកទៅបង្ហាញម្ចាស់ផ្ទះជួល ។

## របៀបដាក់ពាក្យសុំជំនួយ

### អ្នកអាចដាក់ពាក្យសុំជំនួយ ដោយផ្ទាល់ ឬតាមទូរស័ព្ទក៏បានដែរ

មុនពេលអ្នកដាក់ពាក្យសុំជំនួយ អ្នកត្រូវរកឯកសារមួយចំនួន ដូចជា ៖

- ភស្តុតាងបញ្ជាក់អត្តសញ្ញាណរបស់អ្នក
- ព័ត៌មានលម្អិតអំពីប្រាក់ចំណូល និងទ្រព្យសម្បត្តិ របស់អ្នក
- ភស្តុតាងបញ្ជាក់ការចំណាយរបស់អ្នក (ដូចជាថ្លៃរើផ្ទះ ឬថ្លៃជួលផ្ទះ ដែលហួសកាលកំណត់)
- កិច្ចព្រមព្រៀងជួលផ្ទះ របស់អ្នក ។

### ការដាក់ពាក្យសុំជំនួយដោយផ្ទាល់

លោកអ្នកអាចសាកសួរព័ត៌មាននៅមជ្ឈមណ្ឌលសេវាការងារ និងប្រាក់ចំណូលប្រចាំតំបន់រស់នៅរបស់អ្នក ។ តែលោកអ្នកត្រូវធ្វើការណាត់ជួបជាមួយបុគ្គលិកការិយាល័យជាមុនសិនជាការប្រសើរ ។ អ្នកអាចស្វែងរកអាសយដ្ឋានគេហទំព័ររបស់យើងខ្ញុំនៅឯ **workandincome.govt.nz/findus**

### ការដាក់ពាក្យសុំជំនួយតាមទូរស័ព្ទ

ដើម្បីដាក់ពាក្យសុំជំនួយ តាមទូរស័ព្ទ សូមហៅទូរស័ព្ទមកយើងខ្ញុំ ចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 6 ល្ងាច ពីថ្ងៃចន្ទ ដល់ សុក្រ និងចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 1 រសៀល ថ្ងៃសៅរ៍ ។ សូមហៅមកយើងខ្ញុំ តាមលេខ ៖

- **0800 559 009** មនុស្សចាស់នៅធ្វើការបាន
- **0800 552 002** មនុស្សចាស់ជរា
- **0800 88 99 00** និស្សិត

ចំពោះអ្នកដែលទទួលបានជំនួយពីកម្មវិធីប្រាក់ជំនួយសម្រាប់យុវជន ឬប្រាក់ជំនួយសម្រាប់ឪពុកម្តាយវ័យក្មេង សូមទាក់ទងគ្រូបង្រៀនយុវជនរបស់អ្នកដោយផ្ទាល់ ។

ប្រសិនបើអ្នកថ្លង់ ខ្សោយការស្តាប់ ឬពិបាកទំនាក់ទំនងតាមទូរស័ព្ទ អ្នកអាច ៖

- ផ្ញើសារអក្សរមកលេខ ៖ **029 286 7170**
- អ៊ីម៉េលមកកាន់ ៖ **MSD_Deaf_Services@msd.govt.nz**
- ប្រើសេវាបញ្ជូនបន្តរបស់ NZ ៖ **NZRelay.co.nz**

## សម្រាប់ព័ត៌មានបន្ថែម

សូមចូលក្នុង **workandincome.govt.nz/housing**

អ្នកក៏អាចឆែកមើលតាមអនឡាញ ថាតើអ្នកអាចមានសិទ្ធិទទួលបានជំនួយអ្វីខ្លះ នៅឯ **check.msd.govt.nz**

SHA334W-Khmer – OCT 2023